ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០២៥៩......សហវ.......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញនាំចូល ដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា
- បានឃើញប្រកាសអន្តរក្រសួងលេខ ៩៥៤ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**សម្រេច**

**ប្រការ ១._**

ត្រូវបានបង្កើត **"ក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស"** សរសេរជាអក្សរកាត់ថា "**ក.ប.អ.**" ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **នួន ចំន្ទរិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **ម៉ាន់ ចន្នី** | ជំនួយការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងជាប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស | អនុប្រធាន |
| ៤. លោក **សែ សុឃន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. លោក **ឈន ធឿន** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៦. លោក **ធឿន សុជាតិ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៧. លោក **ស៊ីថុន ស៊ីថាណា** | អនុប្រធាននាយកដ្ឋានសវនកម្មគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៨. លោក **ចៅ ម៉ាន់នី** | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៩. លោក **ហ៊ឹម ពុទ្ធិរិទ្ធ** | ប្រធានសាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១០. លោក **ជូ សុចិសុទ្ធ** | ប្រធានការិយាល័យ នៃនាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១. លោក **ហោ ស៊ីណាត** | ជំនួយការ នៃនាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

១២. លោក **ប៊ូ សុធារិទ្ធ** ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋាករ
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៣. លោកស្រី **អ៊ុក ចាន់សុភាព** ប្រធានការិយាល័យ នៃនាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៤. លោក **ឈាយ សុផាន់ណារិទ្ធ** អនុប្រធានការិយាល័យ នៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៥. លោក **ស្រួយ ព្រើត** អនុប្រធានការិយាល័យ នៃសាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៦. លោក **ហ៊ិន ចាន់ថន** អនុប្រធានការិយាល័យ នៃសាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ
នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៧. លោក **គង់ ម៉ារីនម៉ូលីអ៊ា** ជំនួយការ សមាជិក

**ប្រការ ២.-**

**គ.ប.អ.** មានភារកិច្ចដូចខាងក្រោម÷

- ទទួលបន្ទុកអនុវត្តខ្លឹមសារប្រកាសអន្តរក្រសួងលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស
- រៀបចំផែនការសកម្មភាពការងារទាញយកទិន្នន័យព័ត៌មានអ្នកដំណើរជាមុន (Advance Passenger Information - API) និងកំណត់ត្រាឈ្មោះអ្នកដំណើរ (Passenger Name Record - PNR) ដោយប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (Global Travel Assessment System - GTAS)
- ធ្វើការផ្សព្វផ្សាយអំពីការដាក់ឱ្យដំណើរការប្រើប្រាស់ ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ជូនដល់តួអង្គពាក់ព័ន្ធ
- រៀបចំសេចក្តីណែនាំអនុវត្តសម្រាប់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្តល់ទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស
- សហការនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តប្រព័ន្ធ
- ពិនិត្យនិងដោះស្រាយបញ្ហានានា ដែលកើតមានជាយថាហេតុ
- រៀបចំរបាយការណ៍អំពីលទ្ធផលការងារជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ប្រការ ៣.-**

**គ.ប.អ.** មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទបន្ថែម ដើម្បីជួយការងារតាមការចាំបាច់ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការបំពេញការងាររបស់ខ្លួន។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលភារកិច្ចអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៦ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>** ÷

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ